# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ការស្ថាបនាពុទ្ធមណ្ឌលកម្ពុជា (Cambodian Buddhist Center) ទុកជាការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ឲ្យលូតលាស់ចំរើន ។

website : www.hoksavann.org

ថ្ងៃទី២ មីនា ២០០៧



បើគេធ្វើដំណើរតាមផ្លូវជាតិលេខ១ ពីស្ពានមុនីវង្សទៅអ្នកលឿង បានចម្ងាយជាង២០គីឡូម៉ែត្របត់ស្តាំ គេនឹងឃើញពុទ្ធមណ្ឌលកម្ពុជា ដែលស្ថិតនៅក្នុងឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា ។ ពួកទេសចរទាំងក្នុងនិងក្រៅប្រទេសបានទៅធ្វើទស្សនកិច្ចជារៀងរាល់ថ្ងៃ ជាពិសេសនៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ មានចំនួនអ្នកទេសចរច្រើន ដើម្បីទៅនមស្សការបូជនិយដ្ឋាននានា ដែលកសាងនៅក្នុងពុទ្ធមណ្ឌលនោះ ។ បូជនិយដ្ឋានដ៏សំខាន់៤កន្លែងគឺប្រសូត ត្រាស់ដឹង សំដែងធម្មចក្រ និងបរិនិព្វាន។ កន្លែងត្រាស់ដឹងនិងបរិនិព្វានបានកសាងស្ទើរតែរួចរាល់ហើយ នៅតែកន្លែងប្រសូត និងកន្លែងសំដែងធម្មចក្រ កំពុងតែស្ថាបនារាល់ថ្ងៃ ។ ក្រៅពីបូជនិដ្ឋានដ៏សំខាន់បួនកន្លែងនេះ មានសំណង់ផ្សេងៗទៀត គឺព្រះពុទ្ធប្រទានពរ ព្រះពុទ្ធទ្រង់បាត្រ ឧបដ្ឋានសាលា អាស្រមសមាធិ សាលាធម្មវិន័យ សាលាដំណាក់ជាដើម ។ គេឃើញស្រះទឹកជាច្រើនដែលលំអដោយដើមផ្កាព័ទ្ធជុំវិញ និងដើមឫស្សីដុះជាជួរធ្វើជាផ្លូវ ដែលមានមែកកោងរកគ្នាធ្វើជាដំបូលផ្លូវ ដែលជារមណីយដ្ឋានគួររីករាយចិត្ត ។ នៅជិតឧបដ្ឋានសាលាមានដើមត្នោតមួយដើមចម្លែកអស្ចារ្យ គឺមានមែក៨ស្មើគ្នាបែកចេញទៅទិសទាំង៨ ដែលអ្នកប្រាជ្ញព្រះពុទ្ធសាសនាយល់ថា ជាតំណាងអដ្ឋង្គិកមគ្គ គឺមគ្គប្រកបដោយអង្គ៨ ជាផ្លូវប្រតិបត្តិដើម្បីមគ្គផលនិព្វានក្នុងការចេញចា

កទុក្ខ មានជាតិទុក្ខជាដើម ។ បាតុភូតអស្ចារ្យនេះកើតឡើង គួរនឹកដល់ពាក្យចាស់ខ្មែរដែលខ្លះថាពុទ្ធទំនាយថា កាលណាកោះស្លាកែតផុសប្រាសាទមាសប្រាសាទប្រាក់ហើយ ប្រទេសកម្ពុជាយើងនឹងបានសុខសប្បាយ ។ កោះស្លាកែត គឺស្ថិតនៅម៉្តុំនេះឯង ។ ពុទ្ធមណ្ឌលនេះដែលមានទំហំដីជាង១០០ហិកតា កំពុងផុសឡើងនូវបូជនិយដ្ឋាននានាតាមពុទ្ធប្រវត្តិ តាមរចនាបទខ្មែរជាបន្តបន្ទាប់គ្នា ។

ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនាជិតពីរពាន់ឆ្នាំមកហើយ ដែលសព្វថ្ងៃនេះមានវត្តចំនួនបួនពាន់ និងព្រះសង្ឃចំនួនជិតប្រាំមួយម៉ឺនអង្គ ។ ដូច្នេះការបង្កើតឲ្យមានពុទ្ធមណ្ឌលជាការចាំបាច់បំផុត ជាតំណាងវត្តទាំងបួនពាន់ ព្រោះពុទ្ធមណ្ឌលមានទំហំដ៏ធំ ជាខ្នាតអន្តរជាតិ សំរាប់ស្ថាបនាបូជនិយដ្ឋាននានារបស់ព្រះពុទ្ធនិងអាគារផ្សេងៗ សំរាប់បង្រៀនធម៌ និងអប់រំចិត្ត ។ នៅប្រទេសកម្ពុជាមានប្រាសាទរាប់ពាន់ ប៉ុន្តែពុំមែនជាបូជនិយដ្ឋានរបស់ព្រះពុទ្ធសាសនាឡើយ ភាគច្រើនសង់ឡើងឧទ្ទិសចំពោះព្រះអាទិទេពក្នុងសាសនាព្រាហ្មណ៍ ។ ចំណែកប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទដូចប្រទេសកម្ពុជា ដូចជាប្រទេសថៃ ប្រទេសភូមាប្រទេសស្រីលង្កា និងប្រទេសនេប៉ាល់ជាដើម មានពុទ្ធមណ្ឌលដ៏ធំជាខ្នាតអន្តរជាតិជាយូរមកហើយ ។ ភាពក្រីក្រនៃប្រជាពលរដ្ឋខ្មែរ និងការកើតឡើងនៃអំពើហឹង្សាគ្រប់យ៉ាង មកអំពីការធ្លាក់ចុះនៃសីលធម៌ ។ ដូច្នេះការស្ថាបនាពុទ្ធមណ្ឌលនេះឡើងស្របតាមកាលៈទេសៈ ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ជនជាតិខ្មែរ ដែលទុកជាមជ្ឈមណ្ឌលបណ្តុះធនធានមនុស្សក្នុងការសិក្សារៀនសូត្របណ្តុះបញ្ញាស្មារតី ឲ្យមានសីលធម៌ខ្ពស់ឡើងវិញ ។

អ្នកដែលបង្កើតពុទ្ធមណ្ឌលនេះ គឺកើតឡើងពីព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅក្នុងនិងក្រៅប្រទេស ។ បច្ច័យជាវដីជាង១០០ហិកតា កើតឡើងពីសទ្ធាពុទ្ធបរិស័ទខ្មែរនៅក្រៅប្រទេស ។ ចំណែកបូជនិយដ្ឋានទាំង៤កន្លែង គឺកន្លែងប្រសូត ទទួលកសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅប្រទេសអូស្ត្រាលី ដែលដឹកនាំដោយព្រះអង្គស្រី-សុវណ្ណ និងព្រះអង្គនន្ទ-សុទេព, កន្លែងត្រាស់ដឹង កសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទនៅប្រទេសបារាំង ដែលដឹកនាំដោយព្រះអង្គចិត្តការោ ទូចសារិទ្ធ, កន្លែងសំដែងធម្មចក្រកសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិក ដែលដឹកនាំដោយព្រះតេជព្រះគុណ វក្ខិតធម្មោ គង់-សូផាន, កន្លែងបរិនិព្វានកសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅប្រទេសកាណាដា ដែលដឹកនាំដោយលោកឧកញ៉ាឃិត-ឆេង ។ សាលាធម្មវិន័យ កសាងដោយព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរនៅសហរដ្ឋអាមេរិក ដែលដឹកនាំដោយព្រះតេជព្រះគុណាយុន-ហួន ។ មានពុទ្ធបរិស័ទកសាងសំណង់ផ្សេងៗទៀត ប៉ុន្តែមិនបានរៀបរាប់នៅពេលនេះ ។ ក្រុមអភិបាលនៃសមាគមធម្មទូត គឺសម្តេចមហាឃោសនន្ទ ព្រះតេជព្រះគុណាសួស-គូ ព្រះអង្គយស-ហ៊ុត ព្រះអង្គបណ្ឌិតហុក-សាវណ្ណ និងព្រះអង្គទូច-សារិទ្ធ ដឹកនាំ

កសាងពុទ្ធមណ្ឌលនេះ ។ ព្រះអង្គទូច-សារិទ្ធ ជាប្រធានគណៈកម្មការប្រតិបត្តិ ជាអ្នកចាត់ចែងដោយផ្ទាល់នៅទីកន្លែង ។ ចំណែកព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណជាអ្នកចាត់ចែងទូទៅ ដូចជាធ្វើប្លង់ និងទំនាក់ទំនងសាធារណៈជាដើម ។

សំណង់ដែលត្រូវស្ថាបនាបន្តទៅទៀត គឺផ្លូវចូលពីផ្នែកខាងជើងនៃពុទ្ធមណ្ឌល និងស្ពានឆ្លងស្ទឹង ព្រមទាំងក្លោងទ្វារចូលពីផ្លូវជាតិលេខ១, ព្រះវិហារ មណ្ឌលវិបស្សនា សាក្យមុនីចេតិយដំកល់ព្រះសារីរិកធាតុនៃព្រះពុទ្ធ បណ្ណាល័យដំកល់គម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនា និងសៀវភៅវប្បធម៌និងប្រវត្តិសាស្ត្រខ្មែរ សារមន្ទីរសំរាប់ដំកល់វត្ថុបូរាណខ្មែរ កសាងព្រះពុទ្ធរូបដ៏ធំមួយអង្គ កសាងកំពែងព័ទ្ធជុំវិញពុទ្ធមណ្ឌល កសាងស្ថានិយវិទ្យុផ្សាយសម្លេង ។ល។

ក្នុងពុទ្ធមណ្ឌលនោះ ចែកជាពីរផ្នែក គឺមួយផ្នែកកសាងបូជនិយដ្ឋាននានានៃព្រះពុទ្ធ និងមួយផ្នែកទៀតកសាងសំណង់ផ្សេងៗ ដូចជាសាលាធម្មវិន័យ មណ្ឌលវិបស្សនាជាដើម សំរាប់សិក្សារៀនសូត្រ និងអប់រំចិត្ត ។ និមន្តព្រះសង្ឃដែលមានចំណេះពីពុទ្ធិកសិក្សា និងពីសាលាធម្មវិន័យ មកអប់រំបន្ថែមផ្នែកគរុកោសល្យ ឲ្យទៅជាសមណទូត បញ្ជូនទៅទេសនាពន្យល់ធម៌ដល់ពុទ្ធបរិស័ទខ្មែរ នៅតាមខេត្តនិងក្រុងនៃប្រទេសកម្ពុជា ។ មួយផ្នែកទៀត និមន្តលោកគ្រូចៅអធិការ និងអាចារ្យវត្តគ្រប់វត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល មួយក្រុមម្តងមកធ្វើសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពលោកគ្រូចៅអធិការនិងអាចារ្យវត្តទាំងនោះ ឲ្យបំពេញកិច្ចការ ឲ្យបានពេញលេញស្របតាមមុខងាររបស់លោក ។ គឺក្រៅពីសិក្សារៀនសូត្រធម៌វិន័យនិងប្រតិបត្តិតាមឲ្យបានល្អស្របតាមសមណភេទមក លោកគ្រូចៅអធិការនិងព្រះសង្ឃដទៃទៀត គួរពន្យល់ពុទ្ធបរិស័ទខ្មែរជើងវត្តឲ្យយល់តម្លៃគុណធម៌ មានសីលធម៌ជាដើម ឲ្យបានយល់ច្បាស់លាស់ និងជួយផ្នែកសង្គមកិច្ច និងវប្បធម៌ ដូចជាពន្យល់ណែនាំកូនចៅឲ្យខំរៀនសូត្រ កុំដើរលេង ប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ដូចជាល្បែងស្រីជក់គ្រឿងញៀនជាដើម ចំណែកឥពុកម្តាយត្រូវខំប្រឹងប្រែងរកស៊ីធ្វើការងារប្រកបដោយសុចរិត ។ ព្រះសង្ឃក៏អាចដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើមដូចសម័យមុន មិនទាស់ខុសនឹងព្រះវិន័យរបស់ព្រះពុទ្ធសាសនាឡើយ ។ សូមជនជាតិខ្មែរទាំងក្នុងនិងក្រៅប្រទេស ជួយរួមវិភាគទានកសាងពុទ្ធមណ្ឌលកម្ពុជានេះតទៅទៀត ឲ្យបានសំរេចជាស្ថាពរ ទុកជាសម្បត្តិព្រះពុទ្ធសាសនា ដែលជាស្ថាប័នដ៏ធំរបស់ប្រទេសកម្ពុជា ។៚

❑ ❑

❑